**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ចន្ទ ៩ កើត ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ០២ ខែ មីនា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ក្នុងឆ្នាំ ២០១៧-២០១៨

នាព្រឹកថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង **"វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (IDP) ក្នុងឆ្នាំ ២០១៧-២០១៨"** ដែលគ្រោងនឹងគោរពរាយការណ៍ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាពេលខាងមុខនេះ ។ កិច្ចប្រជុំនេះបានការអញ្ជើញចូលរួមពីឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

**"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥"** ដែលត្រូវបានដាក់ចេញ និងកំពុងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីមួយរបស់កម្ពុជា ផ្តោតសំខាន់លើការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព និងជំនាញរបស់កម្លាំងពលកម្មកម្ពុជា ។ គោលនយោបាយនេះ កំណត់នូវចក្ខុវិស័យដើម្បីជំរុញ និងធ្វើទំនើបកម្មឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ ២០២៥ ដោយដាក់ចេញនូវគោលដៅចម្បង ៣ មានជាអាទិ៍៖

- **គោលដៅទី ១៖** កែប្រែ និងពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិដោយបង្កើនអនុបាតវិស័យឧស្សាហកម្មក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ឱ្យបាន ៣០% ដែលក្នុងនោះវិស័យកម្មន្តសាលត្រូវកើនដល់ ២០% នៅឆ្នាំ ២០២៥ ។
- **គោលដៅទី ២៖** បង្កើន និងធ្វើពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនវាយនភណ្ឌ) ឱ្យបាន ១៥% នៃបរិមាណនាំចេញសរុប និងជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ ២០២៥ ។

- **គោលដៅទី ៣÷** ពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម តាមរយៈការជំរុញការចុះបញ្ជីជាផ្លូវការឱ្យបានពី ៨០% ទៅ ៩០% នៅឆ្នាំ ២០២៥ ដែលក្នុងនោះ ៥០% ទៅ ៧០% មានអភិបាលកិច្ចសាជីវកម្មល្អ ដោយមានបញ្ជីកាគណនេយ្យ និងតារាងតុល្យការត្រឹមត្រូវ ។

ជារួម, ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ក្នុងឆ្នាំ ២០១៧ និង ២០១៨ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយផ្អែកលើលទ្ធផលសម្រេចបាននៃគោលដៅទាំង ៣ ខាងលើ ព្រមទាំងវិធានការ ៤ ដែលរួមមាន÷

**១.** ការរៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រីកការលើកទឹកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់,

**២.** ការរៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម,

**៣.** ពង្រីក និងបន្តអភិវឌ្ឍន៍យន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ និង

**៤.** អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណងដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ។

បន្ថែមលើនេះ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងជាការគិតគូរប្រកបដោយបុរេសកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហការជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងរៀបចំទស្សនាទានក្របខណ្ឌតាមដាន និងវាយតម្លៃពាក់កណ្តាលអាណត្តិដែលគ្រោងធ្វើឡើងក្នុងឆមាសទី ១ ឆ្នាំ ២០២១ ។ ក្របខណ្ឌនេះនឹងផ្តល់ការតម្រង់ទិសសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពពាក់កណ្តាលអាណត្តិមួយ ដែលអាចឆ្លុះបញ្ចាំងពីតម្លាតលទ្ធផលសម្រេចបាន និងការរំពឹងទុក និងជាពិសេស ផ្តល់នូវមេរៀន និងបទពិសោធន៍ល្អៗ សម្រាប់ជាធាតុចូលក្នុងការកែតម្រូវវិធីសាស្ត្រ និងវិធានការជាក់លាក់មួយចំនួនដើម្បីសម្រេចបាននូវលទ្ធផលកាន់តែប្រសើរក្នុងរយៈពេលពាក់កណ្តាលអាណត្តិចុងក្រោយ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានខិតខំ និងចូលរួមយ៉ាងសកម្មក្នុងការនាំមុខ និងអនុវត្តវិធានការនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ព្រមទាំងលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តខិតខំ និងផ្តល់កិច្ចសហការ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមមុខសញ្ញា និងភាពពាក់ព័ន្ធរៀងៗខ្លួន។